**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ: ២៥៧
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២
សាលក្រមលេខ: ៣២ (គ)
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។

**ចៅក្រម**

លោកស្រី [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**<u>ដើមចោទ:</u>** ឈ្មោះ [redacted] **ចាន់ឌី** ភេទស្រី កើតឆ្នាំ១៩៨៦ មានអាសយដ្ឋាននៅ [redacted]។

**<u>សហចុងចម្លើយ:</u>**

១. ឈ្មោះ [redacted] **ស្រីមន** ភេទស្រី កើតឆ្នាំ១៩៨៨ មានអាសយដ្ឋាននៅ [redacted]។

២. ឈ្មោះ [redacted] ម៉ៃ ភេទស្រី កើតឆ្នាំ១៩៦២ មានអាសយដ្ឋាននៅ [redacted]

ដោយមានលោកមេធាវី [redacted] អត្តលេខ ២៣៤៩T និងមេធាវី [redacted] អត្តលេខ ២៤៧៨T ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ចាន់ឌី ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

I. **ការទាមទាររបស់ដើមចោទ:** ប្តឹងទាមទារឱ្យតុលាការសម្រេចចេញសាលក្រមមានខ្លឹមសារដូចខាងក្រោម៖

១-បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ៨០០០ USD (ប្រាំបីពាន់ដុល្លាអាមេរិក) មកដើមចោទ ។

២-បង្គាប់ឲ្យសហចុងចម្លើយសងសោហ៊ុយសេវាមេធាវី និងសំណងជម្ងឺចិត្តចំនួន ៣០០០ USD(បីពាន់ដុល្លាអាមេរិក) ។

៣-សុំឱ្យតុលាការប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

II. **ការអះអាងរបស់គូភាគី:**

- មេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ចាន់ឌី សូមធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖ កាលពីថ្ងៃទី២០.០១.២០២១



Scanned with CamScanner

សហចុងចម្លើយឈ្មោះ [redacted] ស្រីមន និងឈ្មោះ [redacted] ម៉ៃ បានខ្ចីប្រាក់ពីកូនក្តីខ្លួន ចំនួន ៨០០០$ ដោយមិនបានធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរនោះទេ គឺខ្ចីដោយផ្ទាល់មាត់ សហចុងចម្លើយក៏បានសន្យាថានឹងសងប្រាក់ដែលខ្លួនបានខ្ចីទៅឲ្យកូនក្តីខ្លួនវិញ នៅថ្ងៃទី១៣.១០.២០២១ ក្រោយមកនៅថ្ងៃទី០១.១២.២០២១ កូនក្តីខ្លួន និងសហចុងចម្លើយបានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាទទួលស្គាល់ និងទូទាត់បំណុលដែលសហចុងចម្លើយបានទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ និងជំពាក់ប្រាក់ពីកូនក្តីខ្លួនចំនួន ៨០០០$ ពិតប្រាកដមែន ហើយថែមទាំងយល់ព្រមសងប្រាក់មកកូនក្តីខ្លួនវិញ នៅថ្ងៃទី១៥.០១.២០២២ ដែលជាពេលវេលាកំណត់ដែលត្រូវសង ប៉ុន្តែដល់ពេលកំណត់នោះ សហចុងចម្លើយមិនបានសងទេ គឺគេចវេសព្រមទាំងធ្វើការពន្យាពេលសងរហូតដល់សព្វថ្ងៃ ទោះបីជាមានការជូនដំណឹងពីកូនក្តីខ្លួន ឲ្យមកធ្វើការទូទាត់ប្រាក់ដែលជំពាក់ក៏ដោយ។ យោងតាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា មាត្រា៥៩១ បានបញ្ញត្តិពីករណីយកិច្ចសងប្រាក់ដើម និងបង់ការប្រាក់របស់អ្នកខ្ចី យោងតាមកិច្ចសន្យាទទួលស្គាល់ និងទូទាត់បំណុលរវាងឈ្មោះ [redacted] ចាន់ឌី និងឈ្មោះ [redacted] ស្រីមន ឈ្មោះ [redacted] ម៉ៃ ចុះថ្ងៃទី០១.១២.២០២១ ត្រង់ប្រការ៣ បានចែងថាក្នុងករណី ភាគី ខ មិនអនុវត្ត រឺខកខានមិនសងតាមប្រការ២ នៃកិច្ចសន្យាខាងលើទេនោះ ភាគី ខ ជាអ្នកបំពានកាតព្វកិច្ចនិង ទទួលស្គាល់ថាជាកំហុសរបស់ខ្លួន ពិតប្រាកដ ហើយភាគី ខ យល់ព្រមឲ្យភាគី ក អាចអនុវត្តតាមផ្លូវច្បាប់ និងរក្សាការពារទ្រព្យរបស់ភាគី ខ បាន និងអាចអនុវត្តលក់ទ្រព្យសម្បត្តិ ភាគី ខ ដោយឡៃឡុងដោយគ្មានការតវ៉ា រឺទាមទារអ្វីទៀតឡើយ ។ សរុបសេចក្តីមកសហចុងចម្លើយបានបំពានកាតព្វកិច្ចខ្លួនយ៉ាងធ្ងន់ធ្ងរ នៅក្នុងកិច្ចសន្យាទទួលស្គាល់ និងទូទាត់បំណុលនិងករណីយកិច្ចរបស់អ្នកខ្ចីពិតប្រាកដ នៃការអនុវត្តកាតព្វកិច្ចនៃកូនក្តីខ្លួន ហេតុដូច្នេះខ្លួនជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទ ស្នើសុំឲ្យតុលាការចេញសាលក្រមតាមកម្មវត្ថុនៃពាក្យបណ្តឹង ចុះថ្ងៃទី០៥.០៤.២០២២ ដោយអនុគ្រោះ ។

- ចុងចម្លើយឈ្មោះ [redacted] ស្រីមន បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមជម្រាបជូនតុលាការថា ឈ្មោះ [redacted] ម៉ៃ ត្រូវជាម្តាយបង្កើតរបស់ខ្លួន ។ គាត់ក៏បានទទួលដីកាកោះរបស់តុលាការដូចខ្លួនដែរ តែគាត់មិនអាចចូលរួមធ្វើនីតិវិធីបានដោយសារគាត់មិនស្រួលខ្លួន។ ខ្លួនសូមទទួលស្គាល់ថាខ្លួនពិតជាបានខ្ចីប្រាក់ពីឈ្មោះ [redacted] ចាន់ឌី ពិតមែន គឺខ្ចីចំនួន ៨០០០$ (ប្រាំបីពាន់ដុល្លារ) ហើយប្រាក់ចំនួន ៨០០០$ នេះគឺខ្លួន ជាអ្នកខ្ចីតែម្នាក់ឯងទេ ចំណែកម្តាយខ្លួន ឈ្មោះ [redacted] ម៉ៃ គឺគាត់គ្រាន់តែចូលរួមផ្តិតមេដៃដឹងលឺតែប៉ុណ្ណោះ ហើយគាត់មិនបានប្រើប្រាស់លុយនោះទេ ។ ខ្លួនសូមជម្រាបថាលុយដែលខ្លួនជំពាក់ឈ្មោះ [redacted] ចាន់ឌី ចំនួន៨០០០$ នោះគឺខ្លួនបានសងគាត់ចំនួន ៤៦០០$(បួនពាន់ប្រាំមួយរយដុល្លារ) ហើយពេលសងប្រាក់ គឺខ្លួនមិនបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរទេ គឺហុចផ្ទាល់ដៃទៅឈ្មោះ [redacted] ចាន់ឌី តែម្តង ហើយពេលសងនោះមិនមានសាក្សីដឹងលឺទេ។ ខ្លួនសងគាត់ចំនួន ៣ដង ។ សងលើកទី១ ចំនួន ១៦០០០០០៛ (មួយលានហុកសិបម៉ឺនរៀល) សងលើកទី២ ចំនួន ៦០០០០០០៛ (ប្រាំមួយលានរៀល)សងលើកទី៣ ចំនួន ១០០០០០០០៛ (ដប់លានរៀល)។ ចំពោះការទាមទាររបស់ដើមចោទដែលសុំឲ្យខ្លួនសងប្រាក់ទៅគាត់ចំនួន ៨០០០$ (ប្រាំបីពាន់ដុល្លារ) គឺខ្លួនយល់ព្រមតាមការទាមទារនេះ ហើយអ្វីដែលខ្លួនលើកឡើងថា ខ្លួនបានសងប្រាក់ទៅគាត់ចំនួន៤៦០០$ រួចហើយគឺខ្លួនគ្រាន់តែចង់អោយគាត់ដឹងប៉ុណ្ណោះ។ ចំពោះការទាមទាររបស់ដើមចោទដែលសុំឲ្យខ្លួនសងសោហ៊ុយសេវាមេធាវី និងសំណងជំងឺចិត្ត



Scanned with CamScanner

ចំនួន ៣០០០$ គឺខ្លួនសូមបដិសេធ ព្រោះខ្លួនគ្មានលទ្ធភាពទេ ។

- ដើមចោទឈ្មោះ [redacted] ចាន់ឌី បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមជម្រាបថាឈ្មោះ [redacted] ស្រីមន បានប្រគល់ប្រាក់មកខ្លួនតែចំនួន ២៤០០$ (ពីរពាន់បួនរយដុល្លារ) ប៉ុណ្ណោះ មិនមែន ៤៦ ០០$ ដូចអ្វីដែលគាត់លើកឡើងនោះទេ ហើយប្រាក់ ២៤០០$ នេះ គឺជាការប្រាក់ដែលគាត់ខ្ចីខ្លួនទេ មិនមែនជាប្រាក់ដើមដែលគាត់សងខ្លួនឡើយ ។

III. **ចំណុចវិវាទ:** ដើមចោទទាមទារឲ្យសហចុងចម្លើយសងសោហ៊ុយសេវាមេធាវី និងសំណងជម្ងឺចិត្តចំនួន ៣០០០ USD (បីពាន់ដុល្លាអាមេរិក) ប៉ុន្តែចុងចម្លើយមិនឯកភាពទេ ព្រោះខ្លួនមិនមានលទ្ធភាព ។

## សំអាងហេតុ

- ដើមចោទប្តឹងទាមទារប្រាក់ដើមពីសហចុងចម្លើយឈ្មោះ [redacted] ស្រីមន និងឈ្មោះ [redacted] ម៉ៃ ចំនួន ៨.០០០(ប្រាំបីពាន់)ដុល្លាអាមេរិក ដោយសំអាងថា កាលពីថ្ងៃទី ២០.០១.២០២១ ឈ្មោះ [redacted] ស្រីមន និងឈ្មោះ [redacted] ម៉ៃ បានខ្ចីប្រាក់ពីខ្លួនចំនួន ៨.០០០(ប្រាំបីពាន់)ដុល្លាអាមេរិក ដោយមិនបានធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរនោះទេ គឺខ្ចីដោយផ្ទាល់មាត់ ហើយសហចុងចម្លើយបានសន្យាថានឹងសងប្រាក់ដែលខ្លួនបានខ្ចីនោះត្រលប់មកអោយដើមចោទវិញ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១។ ក្រោយមក នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ដើមចោទ និងសហចុងចម្លើយបានធ្វើកិច្ចសន្យាទទួលស្គាល់ និងទូទាត់បំណុល ដែលសហចុងចម្លើយទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់ដើមចោទ ចំនួន ៨០០០ USD (ប្រាំបីពាន់ដុល្លារអាមេរិក) និងយល់ព្រមសងប្រាក់ជូនដើមចោទនៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២២ ជាកំណត់ តែនៅពេលដល់ការកំណត់សងសហចុងចម្លើយអត់បានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះទេ ថែមទាំងគេចវេសនិងធ្វើការពន្យាពេលសងរហូតទោះបីមានការជូនដំណឹង អោយមកធ្វើការទូទាត់បំណុលពីដើមចោទច្រើនលើកច្រើនសារក៏ដោយ ។ ចុងចម្លើយឈ្មោះ [redacted] ស្រីមន បានទទួលស្គាល់ថា ខ្លួនពិតជាជំពាក់ដើមចោទឈ្មោះ [redacted] ចាន់ឌី ចំនួន ៨០០០$ ពិតប្រាកដមែន ។

- តាមរយៈកិច្ចសន្យាទទួលស្គាល់ និងទូទាត់បំណុល ចុះថ្ងៃទី០១.១២.២០២១ ឃើញថា ឈ្មោះ [redacted] ស្រីមន និងឈ្មោះ [redacted] ម៉ៃ ពិតជាបានទទួលស្គាល់ថា ពួកខ្លួនបានជំពាក់ប្រាក់ឈ្មោះ [redacted] ចាន់ឌី ចំនួន ៨០០០(ប្រាំបីពាន់) ដុល្លារអាមេរិក ប្រាកដមែន ។

- ដើមចោទទាមទារឱ្យសហចុងចម្លើយសងសោហ៊ុយសេវាមេធាវី និងសំណងជម្ងឺចិត្តចំនួន ៣០០០USD(បីពាន់ដុល្លាអាមេរិក) តែចុងចម្លើយសុំបដិសេធ ព្រោះគ្មានលទ្ធភាពបង់នោះទេ ដូច្នេះ គប្បីពិចារណា ចំពោះការខាតបង់ផលប្រយោជន៍របស់ដើមចោទ និងលទ្ធភាពរបស់ចុងចម្លើយ ។

- ចំពោះប្រាក់ប្រដាប់ក្តីវិញ ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា៦៤ កថាខណ្ឌទី១ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ។



Scanned with CamScanner

- សាលក្រមនេះ ត្រូវភ្ជាប់នូវការប្រកាសអនុវត្តជាបណ្ដោះអាសន្ន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ១៩៦ កថាខណ្ឌទី១ ។

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

**១**-សហចុងចម្លើយឈ្មោះ [redacted]ស្រីមន និងឈ្មោះ [redacted] ម៉ៃ ត្រូវសងប្រាក់ឲ្យទៅដើមចោទឈ្មោះ [redacted] ចាន់ឌី នូវទឹកប្រាក់ដូចខាងក្រោម៖

ក. ប្រាក់ដើមចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក ។

ខ. សំណងជម្ងឺចិត្ត និងសេវាមេធាវីជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន) រៀល។

**២**-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន ត្រង់ចំណុចទី ១ (ក) ប្រាក់ដើម ។

**៣**-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

**៤**-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខភាគីដើមចោទ និងភាគីចុងចម្លើយឈ្មោះ [redacted]ស្រីមន កំបាំងមុខភាគីចុងចម្លើយឈ្មោះ [redacted] ម៉ៃ ។

- ទុកសិទ្ធិឲ្យដើមចោទ និងចុងចម្លើយឈ្មោះ [redacted] ស្រីមន ប្ដឹងឧទ្ធរណ៍រយៈពេល០១ខែ គិតចាប់ពីថ្ងៃបានទទួលអនុសារសាលក្រមនេះ ។
- ទុកសិទ្ធិឱ្យចុងចម្លើយឈ្មោះ [redacted] ម៉ៃ ប្ដឹងទាស់ក្នុងរយៈពេល០២សប្ដាហ៍ គិតចាប់ពីថ្ងៃបានទទួលអនុសារសាលក្រមនេះ និងបន្ថែមរយៈពេល១ខែទៀត សម្រាប់ប្ដឹងឧទ្ធរណ៍គិតចាប់ពីថ្ងៃផុតកំណត់រយៈពេលប្ដឹងទាស់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

កណ្ដាល, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner